ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

លេខ......៣១៦......បទ.ប្រក...............

# ប្រកាស
# ស្តីពី
# ការកំណត់មុខងារនិងភារកិច្ចបន្ថែមរបស់មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១២ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិស័យប្រៃសណីយ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់រដ្ឋមន្ត្រីស្តីទី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីតួនាទី និងភារកិច្ចរបស់រដ្ឋលេខាធិការប្រចាំការ
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការសម្រួលមាត្រា២៦ មាត្រា២៧ មាត្រា២៨ និងមាត្រា២៩ និងបំពេញបន្ថែមមាត្រា២៩ស្ទួន នៃអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ១១០ អនក្រ.បក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការផ្តល់ការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- បានឃើញប្រកាសលេខ ១២៦ បទ.ប្រក ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន មជ្ឈមណ្ឌល និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍

- បានឃើញប្រកាសអន្តរក្រសួងលេខ ១១២០ ប្រក.បទ.សហវ.ចមព ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីអាជ្ញាបណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិ
- បានឃើញប្រកាសរួមលេខ ៤៩៨ សហវ.ប្រក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- យោងតាមការចាំបាច់របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

**សម្រេច**

**ប្រការ១ ._**

ប្រកាសនេះកំណត់អំពីមុខងារនិងភារកិច្ចបន្ថែមរបស់មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍។

**ប្រការ២ ._**

ពាក្យបច្ចេកទេសទាំងឡាយដែលប្រើប្រាស់ក្នុងប្រកាសនេះមានន័យដូចតទៅ៖

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ តទៅសរសេរកាត់ថា "**ក.ប.ទ.**"។

មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ តទៅសរសេរកាត់ថា "**មន្ទីរ ប.ទ.**"។

**លិខិតអនុញ្ញាត** សំដៅលើលិខិតដែល មន្ទីរ ប.ទ. ផ្តល់ជូនអ្នកស្នើសុំ ដើម្បីបំពេញប្រតិបត្តិការដូចមានកំណត់ក្នុងប្រការ៣ នៃប្រកាសនេះ។

**វិទ្យុទាក់ទងលើដីគោក (Push to Talk)** សំដៅដល់បរិក្ខារសម្រាប់ទាក់ទងគ្នាលើដីគោកដោយប្រើរលកអាកាសវិទ្យុ វីអេជ្យអេហ្វនិងយូអេជ្យអេហ្វ (VHF and UHF)។

**បង្គោលអង់តែន (Antenna Tower)** សំដៅដល់បង្គោលឬគ្រោងដែលត្រូវបានធ្វើឡើងដើម្បីបំពាក់អង់តែន។

**វីអេជ្យអេហ្វ (VHF: Very High Frequency)** សំដៅដល់បន្ទាត់ប្រេកង់វិទ្យុចាប់ពី ៣០ ទៅ ៣០០ ម៉េហ្គាហឺត (MHz)។

**យូអេជ្យអេហ្វ (UHF: Ultra High Frequency)** សំដៅដល់បន្ទាត់ប្រេកង់វិទ្យុចាប់ពី ៣០០ ម៉េហ្គាហឺត (MHz) ដល់ ៣ ជីហ្គាហឺត (GHz)

**សាលបម្រើសេវាអ៊ីនធឺណិតកាហ្វេ (Internet Café)** សំដៅដល់ទីកន្លែងបម្រើសេវាអ៊ិនធឺណិតផ្ទាល់ជូនដល់សាធារណជនប្រើប្រាស់អ៊ិនធឺណិត។

**សាខាសេវាបញ្ញើឆាបរហ័សអន្តរជាតិ** សំដៅដល់បុគ្គលទាំងឡាយណាដែលទទួលបានអាជ្ញាបណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិដែលចេញដោយ ក.ប.ទ. ដែលមានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ ហើយមានបំណងបើកសាខាសេវាបញ្ញើឆាប់រហ័សអន្តរជាតិនៅតាមរាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ ឬ/និងឃុំ-សង្កាត់។

**ភ្នាក់ងារប្រៃសណីយ៍ (Postal Agent)** សំដៅដល់បុគ្គលដែលបានស្នើសុំមក ក.ប.ទ. ឬមន្ទីរ ប.ទ ធ្វើជាដំណាងក្នុងការលក់តែមប្រៃសណីយ៍ ឬផលិតផលប្រៃសណីយ៍នៅតាមតំបន់ ឬទីប្រជុំជនដែលគ្មានការិយាល័យប្រៃសណីយ៍ ឬក៏មានការិយាល័យប្រៃសណីយ៍ដែរ ប៉ុន្តែស្នាក់ការលក់នោះត្រូវស្ថិតនៅចំងាយ៥០០ម៉ែត្រពីការិយាល័យប្រៃសណីយ៍។ ភ្នាក់ងារប្រៃសណីយ៍ ទទួលបានកម្រៃជាភាគរយពីការលក់តែមប្រៃសណីយ៍ ឬផលិតផលប្រៃសណីយ៍។

**ព្រឹត្តិការណ៍ពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន** សំដៅដល់ការរៀបចំកិច្ចប្រជុំ សិក្ខាសាលា ឬវេទិកាផ្សេងៗដែលមានខ្លឹមសារ ឬប្រធានបទទាក់ទងនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន។

**ប្រការ៣ ._**

បុគ្គលទាំងឡាយត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនៅ មន្ទីរ ប.ទ. មានសមត្ថកិច្ចដើម្បីបំពេញប្រតិបត្តិការ ពាក់ព័ន្ធនឹងវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានដូចខាងក្រោម៖

១- ការបើកសាខាសេវាបញ្ញើឆាប់រហ័សអន្តរជាតិ

២- ការធ្វើជាភ្នាក់ងារប្រៃសណីយ៍

៣- ការបើកអាជីវកម្មសាលបម្រើអ៊ិនធឺណិត

៤- ការបើកលក់និង/ឬជួសជុលគ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍

៥- ការប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុអេជ្យអេហ្វនិងយូអេជ្យអេហ្វ ដោយគ្រឿងសម្ភារបរិក្ខារវិទ្យុទាក់ទង ដែលមានអានុភាពផ្សាយមិនលើសពី ៦០ វ៉ាត់ (Watt) សម្រាប់ដំណើរការស្ថានីយ៍វិទ្យុទាក់ទងលើដីគោកក្នុង ដែនសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន។

៦- ការលក់គ្រឿងសម្ភារបរិក្ខារកុំព្យូទ័រ ឧបករណ៍អេឡិកត្រូនិកដែលបំពាក់បច្ចេកវិទ្យាគមនាគមន៍និង ព័ត៌មាន ឬសូហ្វវែរ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យអនុក្រឹត្យលេខ ១១០ អនក្រ.បក ចុះថ្ងៃទី២១ ខែ កក្កដា ឆ្នាំ២០១៧ ស្តីពីការផ្តល់ការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

៧- ការរៀបចំព្រឹត្តិការណ៍ពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬ

៨- ប្រតិបត្តិការផ្សេងទៀត ដែលកំណត់ដោយ ក.ប.ទ.។

**ប្រការ៤ ._**

មន្ទីរ ប.ទ. ត្រូវរៀបចំកន្លែងដាក់លាក់មានលក្ខណៈជាច្រកចេញចូលតែមួយ និងមានមន្ត្រីប្រចាំការរៀង រាល់ម៉ោងធ្វើការ សម្រាប់បម្រើសេវាជូនអតិថិជនឱ្យបានល្អប្រសើរ ស្របតាមការកំណត់ក្នុងប្រកាសនេះ និង បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**ប្រការ៥ ._**

មន្ទីរ ប.ទ. ត្រូវប្រមូលប្រាក់ចំណូលដែលទទួលបានពីការចេញលិខិតអនុញ្ញាត ដូចមានកំណត់ក្នុង ប្រកាសនេះ ស្របតាមប្រកាសរួមលេខ ៤៩៨ សហវ.ប្រក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការផ្តល់សេវា សាធារណៈដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ។

រាល់ការទទួលប្រាក់ចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬជាមូលប្បទានប័ត្រលើការប្រមូលចំណូលពី កម្រៃសេវាសាធារណៈដោយមន្ទីរ ប.ទ. ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើ ប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការ គ្រប់គ្រងបង្កាន់ដៃបង់ប្រាក់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៦ ._**

មន្ទីរ ប.ទ. ត្រូវចាត់វិធានការ ឬរាយការណ៍ជាបន្ទាន់មក ក.ប.ទ. ក្នុងករណីពិនិត្យឃើញថាមានការបំពេញប្រតិបត្តិការនានាដោយពុំមានលិខិតអនុញ្ញាត ដូចមានកំណត់ក្នុងប្រកាសនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**ប្រការ៧ ._**

ប្រកាសលេខ ១៣៤ បទ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកំណត់មុខងារនិងភារកិច្ចបន្ថែមរបស់មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវចាត់ទុកជានិរាករណ៍។

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៨ ._**

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ប្រធានវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន អគ្គាធិការ ប្រធានគ្រប់នាយកដ្ឋាន ប្រធានគ្រប់មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ និងប្រធានគ្រប់អង្គភាពទាំងអស់ក្រោមឱវាទក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ អង្គារ ១រោច ខែ ភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**ត្រាំ អ៊ីវតឹក**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត

"ដើម្បីជូនជ្រាប"

- ដូចប្រការ៨

"ដើម្បីអនុវត្ត"

- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ